# វិភាគសាលក្រមព្រហ្មទណ្ឌ

## ករណី "ញុះញង់អោយប្រព្រឹត្តបទល្មើសខូក្រិដ្ឋ ឬ មជ្ឈឹមដោយពុំបានសម្រេចផល"

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤

តាក់តែងដោយ លោកមេធាវី **ហាម ស៊ុនរិទ្ធិ** និងចូលរួមកែសម្រួលដោយក្រុមការងារវិភាគផ្នែកច្បាប់របស់ក្រុមមេធាវីសំរឹទ្ធ (SLG) ដែលជាសមាជិកនៃគណៈមេធាវីព្រះរាជាណាចក្រកម្ពុជា ។*ឈ្មោះ ថ្ងៃខែឆ្នាំ និង ទីតាំងកើតហេតុ ដែលប្រើប្រាស់ក្នុងការវិភាគនេះ គឺការប្រឌិតទេ* ។

# មាតិកា

i. **អង្គហេតុ**

ii. **ភស្តុតាង (សាក្សី ឯកសារ លិខិតអ្នកជំនាញ)**

ក.ភស្តុតាងដាក់បន្ទុក និងអង្គហេតុដែលចោទប្រកាន់ដោយព្រះរាជអាជ្ញា

ខ.ភស្តុតាងដោះបន្ទុក និង អង្គហេតុរបស់ជនជាប់ចោទ

iii. **នីយ័តភាពនៃនីតិវិធី**

ក. ដំណាក់កាលនគរបាលយុត្តិធម៌

ខ. ដំណាក់កាលព្រះរាជអាជ្ញា

គ. ដំណាក់កាលចៅក្រមស៊ើបសួរ

ឃ. មេធាវី ឬអ្នកជំនាញ

ង. ដំណាក់កាលជំនុំជម្រះ

iv. **អង្គច្បាប់**

ក.ការអនុវត្តន៍ច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង ឬធ្ងន់ជាង

ខ. ទ្រឹស្តីធាតុនីត្យានុកូលក្នុងបទល្មើសញុះញង់

ខ.១.ធាតុផ្សំនៃបទល្មើស

ខ.១.១.ធាតុនីត្យានុកូល

ខ.១.២.ធាតុសត្យានុម័ត

ខ.១.៣.ធាតុអត្តនោម័ត

ខ.១.៤.ព្យសនកម្ម

v. **សន្និដ្ឋានសេចក្តីសម្រេចនៃសាលក្រម**

vi. **អនុសាសន៍**

# វិភាគសាលក្រម

<u>ករណី</u> "ញុះញង់អោយប្រព្រឹត្តបទឧក្រិដ្ឋ ឬមជ្ឈឹមដោយពុំបានសំរេចផល"

## I. <u>អង្គហេតុ</u>

- មានអំពើហឹង្សាកាលពីថ្ងៃ២ ខែកក្កដា ឆ្នាំ២០១១ កើតហេតុនៅចំណុចសាលាបឋមសិក្សាត្រពាំង ស្ថិតក្នុងភូមិត្រពាំង សង្កាត់ភូមិធំ ស្រុកសៀមរាប ខេត្តសៀមរាប ។
- អំពើហឹង្សាបានកើតឡើងរវាងក្រុមប្រជាពលរដ្ឋក្នុងសហគមត្រពាំង និង អាជ្ញាធរអប្សរាក្នុងការរារាំងមិនអោយមានការរុះរើ សាលាបឋមសិក្សាត្រពាំង ។
- មិនមានការត្រៀម ឬរៀបចំទុកជាមុន ក្នុងការប្រព្រឹត្តនូវហឹង្សានេះឡើយ ដោយហេតុថាជនជាប់ចោទមិនបានដឹងអំពីគំរោងការរបស់អាជ្ញាធរក្នុងការចុះបេសកកម្មរុះរើជាមុនឡើយ ។
- មិនមានព្យសនៈកម្ម ដែលធ្វើអោយខូចខាតដល់រាងកាយមនុស្ស និងទ្រព្យសម្បត្តិ ដែលកើតចេញបទចោទ ញុះញង់អោយប្រព្រឹត្តបទឧក្រិដ្ឋ ឬមជ្ឈឹមដោយពុំបានសំរេចផល។
- កម្មវត្ថុនៃបទល្មើសជាប្រយោជន៍សាធារណៈ សហគមមានបំណងចង់បានសាលារៀនសំរាប់អោយកុមារ ក្នុងសហគមត្រពាំង បានប្រើប្រាស់ និង ប្រយោជន៍សាធារណៈនៃសហគមនេះ ។ ខាងអាជ្ញាធរធ្វើសកម្មភាពឃាត់ឃាំង ក៏ដើម្បីប្រយោជន៍សាធារណៈ នៃការថែរក្សាសោភណ័ភាពតំបន់ទេសចរ ដើម្បីការពារនូវបេតិកភណ្ឌជាតិ ។

## II. <u>ភស្តុតាង</u>

<u>ក. ភស្តុតាងដាក់បន្ទុក និងអង្គហេតុដែលចោទប្រកាន់ដោយព្រះរាជអាជ្ញា</u>

- កំណត់ហេតុដែលធ្វើឡើយដោយមន្ត្រីនគបាលយុត្តិធមិ
- របាយការណ៍ដែលធ្វើឡើយដោយមន្ត្រីនគរបាលយុត្តិធមិ
- រូបថត ដែលថតបាននៅថ្ងៃកើតហេតុ
- សេចក្តីសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការ តុលាការខេត្តសៀមរាប ក្នុងការចោទប្រកាន់ជនជាប់ចោទទាំង១១នាក់ ក្នុងបទល្មើសញុះញង់អោយប្រព្រឹត្តបទឧក្រិដ្ឋ ឬមជ្ឈឹមដោយពុំបានសំរេចផល ។

អង្គហេតុដែលកើតចេញពីការដាក់អោយស្ថិតក្រោមការពិនិត្យ

- ថ្ងៃ២ ខែកក្កដា ឆ្នាំ២០១០ មានការកើតហេតុមួយនៅចំណុចសាលាបឋមសិក្សាត្រពាំង ស្ថិតក្នុងភូមិត្រពាំង សង្កាត់ភូមិធំ ស្រុកសៀមរាប ខេត្តសៀមរាប ។
- ក្រោយពីការជូនដំណឹង ហាមឃាត់មិនអោយសាងសង់ចំនួនបីដងរួចមកហើយ តែក្រុមសហគម នេះរឹងទទឹង ល្មើសនិងការហាមឃាត់នេះ។
- ការចុះរុះរើមានកំលាំងសមត្ថកិច្ចចំរុះ ដែលមានខាងសមត្ថកិច្ចអាជ្ញាធរអប្សរា ជាអ្នកដឹកនាំ។
- ចាត់ទុកថាសំណង់សាលាបឋមសិក្សាត្រពាំង ជាសំណង់ដែលគ្មានការអនុញ្ញាតិ ពីខាងអជ្ញាធរអប្សរាជាមុន ។
- ជនជាប់ចោទទាំង១១នាក់ ខាងលើធ្វើសកម្មភាព ប្រមូលប្រជាពលរដ្ឋ មកតបតដោយហឹង្សា ដោយគប់ដុំថ្ម និង ដំបង មកលើកំលាំងចុះអនុវត្ត ។
- ជនជាប់ចោទទាំង១១នាក់ ខាងលើដែលមានឈ្មោះដូចជា ១) វាសនា ២) តុលា ៣) មីនា ៤)សក្ក័ ៥)ខ្មៅ ៦) ឈួយ ៧) ពៅ ៨) លីថាវ ៩) ស្រស់ ១០) វុធ ១១) នី គ្មានចេតនាប្រព្រឹត្ត និងមិនបានប្រព្រឹត្តបទចោទ ញុះញង់អោយប្រព្រឹត្តបទឧក្រិដ្ឋ ឬមជ្ឈឹមដោយពុំបានសំរេចផលឡើយ ។
- ជនជាប់ចោទទាំង១១នាក់ ជាអ្នកប្រព្រឹត្តនូវបទចោទនៅថ្ងៃ២ ខែកក្កដា ឆ្នាំ២០១១ មានការកើតហេតុមួយនៅចំណុចសាលាបឋមសិក្សាត្រពាំង ស្ថិតក្នុងភូមិត្រពាំង ស្រុកសៀមរាប ខេត្តសៀមរាប ដោយផ្ទាល់ដើម្បីរាំងមិនអោយមានការរុះរើសាលារៀន ។ តែមិនបណ្តាលអោយនណាម្នាក់រងរបួសឡើយ ។

ខ. ភស្តុតាងដោះបន្ទុក និងអង្គហេតុរបស់ជនជាប់ចោទ

- ដីកាបញ្ជូនទៅជម្រះលេខ២៥៨៣ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៣ របស់ព្រះរាជអាជ្ញាសាលាដំបូងខេត្តសៀមរាប ។
- អវត្តមានសាក្សី មកឆ្លើយបំភ្លឺនាពេលសវនាការក្នុងការស្វែងរកការពិតគ្មានទាំងសាក្សីដាក់បន្ទុក និងទាំងសាក្សីដោះបន្ទុក ។ ហើយក៏មិនមានអាចចម្លើយសាក្សីទាំងពីរប្រភេទនេះ នាពេលសវនាការដែរ ។
- អវត្តមានជនរងគ្រោះក្នុងអំពើចោទប្រកាន់
- រូបថតដែលមានជាភស្តុតាងក្នុងសំណុំរឿង មិនបានបញ្ជាក់ថា ជារូបដែលចេញពីសកម្មភាពរបស់ប្រព្រឹត្តរបស់ជនត្រូវចោទ ។

- គ្មានការចាប់យកវត្ថុតាង ដែលជាឧបករណ៍នៃការប្រព្រឹត្តបទល្មើស ដូចជាដុំថ្ម ដំបង ថាទាំងនេះត្រូវបានកាន់កាប់ដោយនិង ប្រើប្រាស់ដោយជនជាប់ចោទ ។

<u>អង្គហេតុដែលកើតចេញអំពីចម្លើយរបស់ជនជាប់ចោទ</u>

- ថ្ងៃ២ ខែកក្កដា ឆ្នាំ២០១១ មានការកើតហេតុមួយនៅចំណុចសាលាបឋមសិក្សាត្រពាំង ស្ថិតក្នុងភូមិត្រពាំង ស្រុកសៀមរាប ខេត្តសៀមរាប ។
- មានក្រុមអាជ្ញាធរអេប្បរ៉ាចុះរុះរើសាលារៀន ដោយខ្លួនមិនបានដឹងទុកជាមុន
- ក្រុមអាជ្ញាធរដេញចាប់មនុស្ស និង បង្ក្រាបមិនអោយសាងសង់
- ក្នុងពេលដែលសាលារៀនកំពុងសាងសង់ ពិតជាមានអំពើហឹង្សាកើតមានឡើង រវាងអាជ្ញាធរ និង ប្រជាពលរដ្ឋ តែមិនមានរាយការណ៍អំពីអ្នករងគ្រោះរងគ្រោះឡើយ ។
- ដីសាងសង់សាលានៅមានទំនាស់នៅឡើយរវាងសហគមត្រពាំង និងអាជ្ញាធរអេប្បរា។
- ជនជាប់ចោទទាំង១១ នាក់ ដែលមានឈ្មោះ ១) វាសនា ២) តុលា ៣) មីនា ៤) សក្ក័ ៥) ខ្មៅ ៦) ឈួយ ៧) ពៅ ៨) លីថាវ ៩) ស្រស់ ១០) វុធ ១១) នី គ្មានចេតនាប្រព្រឹត្ត និង មិនបានប្រព្រឹត្តបទចោទ ញុះញ៉ង់អោយប្រព្រឹត្តបទឧក្រិដ្ឋ ឬមជ្ឈឹមដោយពុំបានសំរេចផលឡើយ ។

III. <u>**នីយ័តភាពនៃនីតិវិធី**</u>

**ក. ដំណាក់កាលនគរបាលយុត្តិធម៏**

- របាយការណ៍ ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១១ និង
- កំណត់ហេតុ ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១១
  ស្របតាមមាត្រា៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ស្តីពីកំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន បានចែងថា៖ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន។

**ខ. ដំណាក់កាលព្រះរាជអាជ្ញា**

- ដីកាបញ្ជូនរឿងទៅជម្រះ មិនមែនជាសមត្ថកិច្ចរបស់ព្រះរាជអាជ្ញាទេ វាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរសុទ្ធសាធ [ក្នុងករណីសំណុំរឿងដែលមានដីកាបញ្ជូនរឿងអោយស៊ើបសួរ] ។ យោងដីកាបញ្ជូនទៅជម្រះលេខ ៦២៧៩ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៤ របស់ព្រះរាជអាជ្ញាសាលាដំបូងខេត្តសៀមរាប។ យោងតាមមាត្រា ២៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌស្តីពីការបញ្ជូនដើម្បីបើកសវនាការជំនុំជម្រះ"**ប្រសិនបើចៅក្រម**

តាក់តែងដោយ លោកមេធាវី **ហម ស៊ុនរិទ្ធិ** និងចូលរួមកែសម្រួលដោយក្រុមការងារវិភាគផ្នែកច្បាប់របស់ក្រុមមេធាវីសិទ្ធិ (SLG) ដែលជាសមាជិកនៃគណៈមេធាវីព្រះរាជាណាចក្រកម្ពុជា ។*<u>ឈ្មោះ ថ្ងៃខែឆ្នាំ និង ទីតាំងកើតហេតុ ដែលប្រើប្រាស់ក្នុងការវិភាគនេះ គឺការប្រឌិតទេ</u>* ។

**ស៊ើបសួរសម្រេចចេញដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងជាបន្ទាន់ទៅប្រធានតុលាការ ដើម្បីកំណត់ពេលសវនាការជំនុំជម្រះ"**

- តួនាទីរបស់ព្រះរាជអាជ្ញាគឺ ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់ យោងតាមមាត្រា [២៧ ក្រនព្រ]។

- មានតែចៅក្រមស៊ើបសួរតែមួយគត់ ដែលមានសមត្ថកិច្ច ចេញដីកាដំណោះស្រាយក្រោយពីបិទកិច្ចស៊ើបសួរ។ ដីការដំណោះស្រាយអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីការលើកលែងចោទប្រកាន់ ។ [មាត្រា២៤៧ក្រ.ន.ព្រ] ។

## គ. ដំណាក់កាលចៅក្រមស៊ើបសួរ

- ប្រសិនបើព្រះរាជអាជ្ញា ចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះមែន ជាកំហុសអនីយ័តភាពនៃនីតិវិធី ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។
  របៀបប្តឹងទៅតុលាការ ក្នុងសំណុំរឿងនេះគឺខុសនឹងគតិច្បាប់ហើយ យោងមាត្រា [២៩១ ក្រនព្រ] ក្នុងរឿងព្រហ្មទណ្ឌសាលាដំបូង ត្រូវបានទទួលបណ្តឹងដោយ [ដីការបញ្ជូនរបស់ចៅក្រមស៊ើបសួរ...]
- មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ [មាត្រា២៥២] នាំអោយមានមោឃភាពផងដែរ កាលណាការបំពានវិធាន ឬទម្រង់ការសំខាន់ណាមួយ ដែលចែងដោយក្រមនេះ ឬបទបញ្ញត្តិទាំងឡាយស្តីពីនីតិវិធីព្រហ្មទណ្ឌធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍របស់ ភាគីដែលទទួលរងការបំពាននេះ។
- ដោយយោងទៅលើអំណះអំណាងខាងលើនេះ សាលក្រមលេខ ៧០២ ចុះថ្ងៃទី១១ សីហា ឆ្នាំ២០១០នៃសាលាដំបូងសៀមរាប ជាសាលក្រមខុសនិងគតិច្បាប់នីតិវិធី ដូច្នេះសាលក្រមនេះនិងមិនមានសុពលភាពខាងផ្លូវច្បាប់ ដើម្បីអនុវត្តឡើយ ។

## ឃ. មេធាវី ឬអ្នកជំនាញ

- មេធាវីការពារឲ្យជនជាប់ចោទទាំង១១ នាក់ ត្រូវពិនិត្យមើលអំពីនីយ័តភាពនៃនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ ដើម្បីប្តឹងសុំតាមមាត្រា២៥២ នៃក្រមន ស្តីពីមោឃភាពនៃការមិនគោរពតាមវិធានបញ្ញត្តិ។
  យោងតាមមាត្រា ២៦១ នៃក្រមន ស្តីពីការពិនិត្យលើនិយ័តភាពនៃនីតិវិធីដែលត្រូវបានពិនិត្យមើលដោយសភាស៊ើបសួរ។

- មេធាវីការពារឲ្យជនជាប់ចោទទាំង១១ នាក់ ក៏មានសិទ្ធិផងដែរក្នុងការស្នើសុំទៅចៅក្រមជំនុំជម្រះនាពេលសវនាការដើម្បីកោះហៅសាក្សី ដែលជាអ្នកជំនាញមកឆ្លើយបំភ្លឺនាពេលសវនាការ ដោយយោងតាមមាត្រា ៣២៤ នៃក្រមន ស្ដីពីការស្ដាប់ចម្លើយរបស់សាក្សីដែលមិនត្រូវបានកោះហៅនាពេលសវនាការ។
- យោងតាមមាត្រា ៣២៦ នៃក្រមន ស្ដីពីការស្ដាប់ចម្លើយរបស់ភាគីបានចែងថា "ប្រធានសវនាការស្ដាប់ចម្លើយដើមបណ្ដឹង អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ តាមលំដាប់លំដោយដែលខ្លួនយល់ថាមានប្រយោជន៍"។

**ង. ដំណាក់កាលចៅក្រមជំនុំជម្រះ**

- អវត្តមានជនជាប់ចោទ នាពេលសវនាការ តុលាការស្ដាប់ការអានចម្លើយ របស់ជនជាប់ចោទ ដែលមានក្នុងកំណត់ហេតុនៃសំណុំរឿង ។ ដែលជាកត្តាមួយនៃការខកខានរបស់ចៅក្រម ក្នុងការស្វែងយល់រកការពិត អំពីចេតនាប្រព្រឹត្តនៃជនជាប់ចោទ និងការពិតក្នុងសំណុំរឿងទាំងមូល ។ យោងមាត្រា៩៨ នៃក្រមន ស្ដីពីជំនួយមេធាវីនាពេលឃាត់ខ្លួន និងមាត្រា ៣២២ ស្ដីពីសិទ្ធិការពារខ្លួនរបស់ជនជាប់ចោទនាពេលសួរដេញដោល។
ពុំបានបញ្ជាក់អំពីអវត្តមានរបស់គូភាគី។ ជាពិសេសភាគីជនជាប់ចោទទាំង ១១នាក់ របៀបនៃកោះ មាត្រា ២៣២ ២៣៨ និង ២៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

- ជនជាប់ចោទ អវត្តមាន ព្រមទាំងគ្មានមេធាវីការពារសិទ្ធិ (រំលោភលើសិទ្ធិ នៃការទទួលបាននូវសវនាការដោយសេរី និង យុត្តិធម៌)។ យោងមាត្រា១០ នៃសេចក្ដីថ្លែងការណ៍ជាសកលស្ដីពីសិទ្ធិមនុស្ស " *មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នាពេញលេញ សុំអោយតុលាការឯករាជ្យ និង មិនលំអៀង ពិនិត្យរឿងក្ដីរបស់ខ្លួនជាសាធារណៈ និងដោយសមធម៌ ដើម្បីសម្រេចសិទ្ធិ និង កាតព្វកិច្ច និង ភាពសមហេតុសមផល នៃការចោទប្រកាន់ទាំងឡាយខាងបទល្មើសព្រហ្មទណ្ឌមកលើខ្លួន* "។

- តុលាការខកខានមិនបានស្ដាប់ចម្លើយនៃសាក្សីទាំងដាក់បន្ទុក និងដោះបន្ទុក ដែលជាហេតុនាំអោយ តុលាការមិនបានធ្វើការផ្ទៀងផ្ទាត់គ្រប់ជ្រុងជ្រោយ លើភាពច្បាស់លាស់ និង គ្មានការសង្ស័យនៃអង្គហេតុ ។ [មាត្រា៣៥៧ ការសរសេរសាលក្រម] ផ្នែកសំរេចសេចក្ដីរបស់តុលាការ អង្គហេតុត្រូវតែច្បាស់លាស់ និងគ្មានការ

សង្ស័យ ។ តុលាការត្រូវមើលបទចោទនីមួយៗ និង ទឡ្ហីករណ៍ដែលបានលើកឡើង នាពេលសវនាការ ។ មាត្រា ១៥៣ ៣១៥ ៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

- គ្មានភស្តុតាងដែលជាឧបករណ៍ក្នុងការប្រព្រឹត្តបទល្មើស ដូចជាដុំថ្ម ដំបង មិនត្រូវបានគេយកមកបង្ហាញនាពេលសវនាការជាសាធារណៈឡើយ ។ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា" **វិមតិសង្ស័យត្រូវបានជាប្រយោជន៍ជនជាប់ចោទ**"។
- ក្នុងករណីអវត្តមានជនជាប់ចោទក៏ដោយ ចៅក្រមជំនុំជម្រះមានតួនាទីស្វែងរកឲ្យឃើញការពិត ដោយស្តាប់ចម្លើយភាគីដទៃទៀត សាក្សី និងពិនិត្យភស្តុតាង យោងតាមមាត្រា ៣៣៣ ក្រមន។

## IV. អង្គច្បាប់

### ក. ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង ឬ ធ្ងន់ជាង

- ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង ឬ ធ្ងន់ជាង មាត្រា ១០ នៃក្រមព្រហ្មទណ្ឌថ្មី ឆ្នាំ២០០៩ "បទបញ្ញត្តិថ្មីចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម"។ យោងមាត្រានេះ តំណាងអយ្យការ និង តុលាការត្រូវតែពិនិត្យក្នុងបទល្មើសដែលមានចែងក្នុងមាត្រា៤៩៤ និង មាត្រា៤៩៥ នៃក្រមនេះ ដោយហេតុថាក្រមព្រហ្មទណ្ឌថ្មីកំណត់ទណ្ឌកម្ម ស្រាលជាង ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ក្រមព្រហ្មទណ្ឌថ្មីត្រូវកំណត់ ទណ្ឌកម្មអប្បរាត្រឹម៦ខែ ដល់២ឆ្នាំ ចំណែកច្បាប់ព្រហ្មទណ្ឌអន្តរកាលកំណត់អប្បរានៃទោស ១ឆ្នាំ និង អតិប្បរមានៃទោស រហូតដល់ប្រាំឆ្នាំឯណោះ ។

យោងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា១០.២ "ដូចគ្នានេះដែរមិនត្រូវមានការផ្តន្ទាទោសអោយធ្ងន់ជាងទោស ដែលបានកំណត់អោយអនុវត្តក្នុង កំឡុងពេលដែលបទល្មើសបានកើតឡើង ឡើយ" ។

យោងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាន មាត្រា១៥.១ "ប្រសិនបើការក្រោយពីការប្រព្រឹត្តបទល្មើសហើយ ច្បាប់បានបញ្ញត្តិអោយមានការដាក់ទោសស្រាលជាងមុន ជនល្មើសត្រូវទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលជាងមុន"

យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាង មាត្រា៣១ "ព្រះរាជាណាចក្រ កម្ពុជា ទទួលស្គាល់ និង គោរពសិទ្ធិមនុស្ស" ដូចមានចែងក្នុង រដ្ឋធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាស

ជាសកលស្តីពីសិទ្ធិ មនុស្ស និង កតិការសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនិង សិទ្ធិមនុស្ស សិទ្ធិនារី និង សិទ្ធិកុមារ លើសពីនេះទៅទៀតផ្តន្ទាទោសទោសធ្ងន់ជាង មាត្រា៩ សេចក្តីថ្លែងការណ៍ និង មាត្រា១៥ សិទ្ធិពលរដ្ឋ។

ហេតុដូចនេះខ្ញុំនឹងធ្វើការវិភាគលើអង្គច្បាប់ នៃបទល្មើសញុះញង់ តែក្នុងមាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ តែប៉ុណ្ណោះ ។

## ខ. ទ្រឹស្តីធាតុនីត្យានុកូលក្នុងបទល្មើសញុះញង់

### ខ.១. ធាតុផ្សំនៃបទល្មើស

#### ខ.១.១.ធាតុនីត្យានុកូល

តាមទ្រឹស្តីនៃការញុះញង់ *<u>បទល្មើសត្រូវតែប្រព្រឹត្តិនៅទីសាធារណៈ</u>*។

*<u>និយមន័យនៃការញុះញង់ យោងតាមមាត្រា ៤៩៤ នៃក្រមព្រហ្មទណ្ឌ</u>*

ដើម្បីអនុវត្តផ្នែកនេះ ការញុះញង់អាចត្រូវផ្តន្ទាទោស កាលបើអំពើនោះត្រូវបានប្រព្រឹត្តៈ

១.ដោយសំដី តាមប្រភេទណាក៏ដោយ ដែលត្រូវផ្សព្វផ្សាយក្នុងចំណោមសាធារណៈ ឬនៅក្នុងពេលប្រជុំជាសាធារណៈ។

២.ដោយសំណេរ ឬគំនូរ តាមប្រភេទណាក៏ដោយ ដែលត្រូវផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន ឬតាំងឲ្យសាធារណៈជនមើល។

៣.ដោយគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន។

ភាពសាធារណៈនៃអំពើ៖ ដើម្បីឲ្យអ្នកញុះញង់មួយត្រូវបានដាក់ទណ្ឌកម្មតាមមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ ការនិយាយ ឬកាយវិការ ត្រូវតែធ្វើនៅទីសាធារណៈ។ ខាងក្រោមនេះអាចចាត់ទុកជាទីសាធារណៈ៖

- ទីកន្លែងសាធារណៈ (ឧទាហរណ៍ ទីលានសាធារណៈ)
- ការប្រជុំសាធារណៈ (ដូចជា ការប្រមូលផ្តុំគ្នា ការធ្វើបាតុកម្ម)
- ផ្ទាំងក្តា ឬប៉ាណូផ្សព្វផ្សាយ
- សោតទស្សន៍ព័ត៌មាន។

ប្រភេទនៃគមនាគមន៍៖ អាចធ្វើឡើងដោយ និយាយពាក្យសំដី ការសរសេរ គំនូរ ឬ ការផ្សព្វផ្សាយ តាមរយៈសារព័ត៌មាន។

តាមមាត្រា៤៩៥ នៃ ក្រមព្រហ្មទណ្ឌ បានចែងថា:

"អំពើញុះញង់ដោយផ្ទាល់ឲ្យប្រព្រឹត្តបទក្រិដ្ឋជាអាទិ៍ ឬប្រព្រឹត្តអំពើបង្កឲ្យមានភាពវិកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម តាមមធ្យោបាយណាមួយ ក្នុងចំណោមមាត្រាដែលមានចែងក្នុងមាត្រា ៤៩៤ នៃ ក្រមព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ ខែ ទៅ២ ឆ្នាំ និងពិន័យជាប្រាក់ពី១.០០០.០០០ (មួយលានរៀល) ទៅ ៤.០០០.០០០ (បួនលានរៀល)"។

### ខ.១.២. ធាតុសត្យានុម័ត

- ពុំមានអំពើញុះញង់ដោយផ្ទាល់ឲ្យប្រព្រឹត្តបទក្រិដ្ឋជាអាទិ៍ ឬប្រព្រឹត្តអំពើបង្កឲ្យមានភាពវិកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម តាមមធ្យោបាយណាមួយ ដូចមានចែងក្នុងមាត្រា ៤៩៤ នៃក្រមព្រហ្មទណ្ឌ។
- មានអំពើហឹង្សាកាលពីថ្ងៃ២ ខែកក្កដា ឆ្នាំ២០១០ កើតហេតុនៅចំណុចសាលាបឋមសិក្សាត្រពាំង ស្ថិតក្នុងភូមិត្រពាំង សង្កាត់ភូមិធំ ស្រុកសៀមរាប ខេត្តសៀមរាប ។
- អំពើហឹង្សាបានកើតឡើងរវាងក្រុមប្រជាពលរដ្ឋក្នុងសហគមត្រពាំង និង អាជ្ញាធរអប្សរាក្នុងការរារាំងមិនអោយមានការរុះរើ សាលាបឋមសិក្សាត្រពាំង ។
- មិនមានការត្រៀម ឬរៀបចំទុកជាមុន ក្នុងការប្រព្រឹត្តនូវហឹង្សានេះឡើយ ដោយហេតុថាជនជាប់ចោទមិនបានដឹង អំពីគំរោងការរបស់អាជ្ញាធរក្នុងការចុះបេសកកម្មរុះរើជាមុនឡើយ ។

### ខ.១.៣. ធាតុផ្សំអត្តនោម័ត

ដើម្បីដាក់ទណ្ឌកម្មលើបទល្មើសញុះញង់ដោយផ្ទាល់និងសាធារណៈបាន គេត្រូវរកឲ្យឃើញនូវចេតនារបស់អ្នកញុះញង់ដើម្បីញ៉ាំងឲ្យមនុស្សផ្សេងទៀតដុះគំនិតដើម្បីប្រព្រឹត្តបទល្មើស ឬធ្វើឲ្យមនុស្សផ្សេងនោះមានការចាប់ចិត្តនឹងបទល្មើស ដែលអ្នកញុះញង់បានអំពាវ នាវ។

និយាយម្យ៉ាងទៀតគឺថា ការញុះញង់គឺជាល្បិចដែលធ្វើដោយដឹងខ្លួន ដែលមានគោលដៅធ្វើឲ្យកើតចិត្តរំភើបខ្លាំងនិង បង្កើតមានផ្នត់គំនិត ដែលឈានទៅរកបទល្មើស ។ ដូច្នេះ អ្នកញុះញង់ត្រូវតែមានចេតនាជាក់លាក់ មិនមែនជាការឆ្លោយមាត់ ដោយធ្វេសប្រហែស ឬនិយាយលេងនោះទេ។ ពាក្យសំដី ឬកាយវិការញុះញង់ត្រូវមានលក្ខណៈច្បាស់គ្មានប្រឡំ ដែលនឹងធ្វើឲ្យអ្នកដែលទទួលសារញុះញង់យល់ច្បាស់ថាខ្លួនត្រូវធ្វើអ្វី ដើម្បីឆ្លើយតបទៅនឹងការញុះញង់នោះ។ នេះជាការផ្តិតចេតនារបស់អ្នកញុះញង់បញ្ចូលទៅក្នុងចិត្តរបស់អ្នកដែលរងការញុះញង់។ អ្នកញុះញង់ត្រូវមានការដឹងយ៉ាងពេញលេញនូវអ្វីដែលខ្លួនកំពុងធ្វើ និងអ្វីដែលនឹងកើតមានឡើង។

នៅក្នុងសំណុំរឿងលេខ ០០១ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីឲ្យការញុះញង់កើតមានបាន "ជនសង្ស័យត្រូវតែមានចេតនាចង់បង្ក ឬញ៉ាំង [អ្នកផ្សេង] ឲ្យប្រព្រឹត្តបទល្មើស ឬត្រូវបានដឹងពីអភិភវនីយភាព [ភាពទំនងយ៉ាងខ្លាំង] ថាបទល្មើសមួយនឹងត្រូវបានប្រព្រឹត្តតាមការញុះញង់"

ទោះបីមានមូលហេតុ និងគោលដៅចុងក្រោយយ៉ាងណាក៏ដោយ អ្នកញុះញង់ត្រូវតែមានឆន្ទៈជំរុញឲ្យបង្កើតចិត្តតែម្យ៉ាងដើម្បីជំរុញឲ្យមានការប្រព្រឹត្តដែលធ្វើឲ្យខូចខាតដល់ជីវិត ឬ បូរណភាពរាងកាយរបស់មនុស្ស ឬមួយអ្នកបង្កដឹងថាពាក្យដែលខ្លួននិយាយ ឬសំណេរដែលខ្លួនផ្សព្វផ្សាយអាចធ្វើឲ្យអ្នកណាម្នាក់ប្រព្រឹត្តបទល្មើស ។ ការប្រើអត្ថបទមួយដែលមានសណ្ឋានជាបង្កការរករឿង) ជេរប្រមាថ និង ហិង្សា ដោយគ្មានភស្តុតាង ឬ សញ្ញាណាមួយដែលធ្វើឲ្យគេសន្មតលើអ្នកនិពន្ធ និងអ្នកបកប្រែ ថាមានឆន្ទៈ ធ្វើឲ្យសាធារណជនមានចិត្ត និងបានឱកាសប្រព្រឹត្តអំពើធ្វើឲ្យប៉ះពាល់ដល់ជីវិត ឬ បូរណភាពរាងកាយរបស់អ្នកដទៃ (មន្ត្រីប៉ូលីស និងតំណាងរដ្ឋ) មិនទាន់គ្រប់គ្រាន់ដើម្បីចាត់ទុកថាជាធាតុផ្សំអត្តនោម័តនៃបទល្មើសដែលចោទប្រកាន់នោះទេ។

ដើម្បីអាចផ្តន្ទាទោសបាន ការបង្កដែលគ្មានផល ត្រូវតែជាការញុះញង់ដោយផ្ទាល់ មិនមែនតែនៅក្នុងស្មារតីប៉ុណ្ណោះទេ តែត្រូវចេញជាពាក្យសំដីផងដែរ ថាឲ្យប្រព្រឹត្តអំពើជាក់ស្តែងជាកំណត់ ហើយអំពើនោះជាធាតុផ្សំនៃបទល្មើសណាមួយ ។

យ៉ាងណាមិញ ធាតុសត្យានុម័តក្នុងសំណុំរឿងនេះ តុលាការខកខានក្នុងបង្ហាញនូវ ចេតនាប្រព្រឹត្តនៃជនជាប់ចោទទាំង១១ នាក់ និង ជាពិសេសគឺសកម្មភាពប្រព្រឹត្តបទល្មើស មិនត្រូវបានរកឃើញដោយផ្ទាល់ថា ជនទាំង១១ នាក់នេះបានធ្វើអំពើអ្វីខ្លះនៅថ្ងៃកើតហេតុ ។

### ខ.១.៤. ព្យសនកម្ម

គ្មានព្យសនកម្មណាមួយ ត្រូវបានលើមកពិភាក្សាក្នុងសាលក្រមនេះឡើយ ទោះបីជាយើងបានឃើញនៅក្នុងសំអាងហេតុរបស់ចៅក្រមជំនុំជម្រះ [បង្ហាញនូវការយល់ឃើញរបស់ខ្លួនថា ជនជាប់ចោទទាំង១១ នាក់ ពុំបានប្រព្រឹត្តអ្វីដែលធ្វើអោយប៉ះពាល់ធ្ងន់ធ្ងរដល់ក្រុមអាជ្ញាធរអប្សរាទេ មិនតែប៉ុណ្ណោះមិនបានធ្វើអោយអ្នកណាម្នាក់របួសឡើយ] ក៏យើងនៅតែមិនឃើញនូវព្យសនកម្មណាមួយ ដែលកើតចេញពីអំពើញុះញង់ឡើយ ។ ហេតុដូចនេះ ការចោទប្រកាន់ក្នុងសំណុំរឿងនេះនៃបទចោទញុះញង់ គឺមិនអាចនាំអោយមានការចោទប្រកាន់បានទេ ដោយហេតុថាធាតុផ្សំនៃបទល្មើសមិនត្រូវបានបំពេញគ្រប់គ្រាន់ទៅតាមគោលការណ៍នៃធាតុផ្សំបទល្មើស ដែលមាន ធាតុនីត្យានុកូល ធាតុអត្តនោមត្ត័ និងធាតុសំភារៈ [គឺការខូចខាត] ។

## V. <u>សន្និដ្ឋានសេចក្តីសម្រេចនៃសាលក្រម</u>

### ក. ចំនុចវិជ្ជមាននៃសេចក្តីសម្រេច

- បានប្រើប្រាស់នូវស្ថានសំរាលបានត្រឹមត្រូវតាមគតិច្បាប់ នៃមាត្រា៩៣ កថាខណ្ឌ១ និង មាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ ។ ការប្រើប្រាស់នូវស្ថានសំរាលនេះ គឺជាឆន្ទានុសិទ្ធិស្រប ច្បាប់ ដែលផ្តល់នូវប្រយោជន៍នៃការអនុវត្តសិទ្ធិពលរដ្ឋ ដូចចែងក្នុងរដ្ឋធម្មនុញ្ញ សេចក្តី ប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ។
- សមាសភាពនៃអង្គជំនុំជម្រះត្រូវបានធ្វើឡើងស្របនិងគតិច្បាប់ នៃមាត្រា២៨៩ នៃក្រន ព្រ ស្រាលាដំបូងសម្រេចជាចៅក្រមទោលចំពោះបទមជ្ឈឹម និង បទលហុ ។ ជាសក្ខីភាព សមាសភាពចៅក្រមជំនុំជម្រះត្រូវបានធ្វើឡើងដោយចៅក្រមទោល ហើយបទល្មើស ដែលយកមកជម្រះ ជាបទមជ្ឈឹម ។
- សាលក្រមបានទុកសិទ្ធិអោយជនជាប់ចោទដែលកំបាំងមុខ មានសិទ្ធិប្តឹងទាស់ និង ប្តឹង ឧទ្ធរណ៍ ។ ការទុកសិទ្ធិអោយបែបនេះត្រូវនឹងគតិច្បាប់នៃមាត្រា៣៦៥ " បណ្តឹងទាស់ ចំពោះសាលក្រមកំបាំងមុខ ពិរុទ្ធជនអាចធ្វើបណ្តឹងទាស់នឹងសាលក្រមដែលប្រកាស ដោយកំបាំងមុខខ្លួនបាន "។

### ខ. ចំនុចអវិជ្ជមាននៃសេចក្តីសម្រេច

- ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង ឬ ធ្ងន់ជាង មាត្រា១០ នៃក្រមព្រហ្មទណ្ឌថ្មី ឆ្នាំ២០០៩ "បទបញ្ញត្តិថ្មីចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម"។ យោងមាត្រា នេះ តុលាការត្រូវតែធ្វើការវិនិច្ឆ័យសេចក្តី ដោយផ្អែកលើបទល្មើស ដែលមានចែងក្នុង មាត្រា៤៩៤ និង មាត្រា៤៩៥ នៃក្រមនេះ ដោយហេតុថាក្រមព្រហ្មទណ្ឌថ្មីកំណត់ ទណ្ឌកម្ម ស្រាលជាងច្បាប់ព្រហ្មទណ្ឌអន្តរកាល។ ក្រមព្រហ្មទណ្ឌថ្មីត្រូវកំណត់ ទណ្ឌកម្មអប្បរាត្រឹម៦ខែ ដល់២ឆ្នាំ ចំណែកច្បាប់ព្រហ្មទណ្ឌអន្តរកាលកំណត់អប្បរានៃ ទោស ១ឆ្នាំ និង អតិប្បរមានៃទោស រហូតដល់ប្រាំឆ្នាំ ឯណោះ ។

យោងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា១០.២។

យោងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោយមាត្រា ១៥.១ ផ្តន្ទាទោស ទោសធ្ងន់ជាង។

យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាង មាត្រា៣១ ។

---

តាក់តែងដោយ លោកមេធាវី **ហាម ស៊ុនរិទ្ធិ** និងចូលរួមកែសម្រួលដោយក្រុមការងារវិភាគផ្នែកច្បាប់របស់ក្រុមមេធាវីសំរឹទ្ធ (SLG) ដែលជាសមាជិកនៃគណៈ មេធាវីព្រះរាជាណាចក្រកម្ពុជា ។<u>*ឈ្មោះ ថ្ងៃខែឆ្នាំ និង ទីតាំងកើតហេតុ ដែលប្រើប្រាស់ក្នុងការវិភាគនេះ គឺការប្រឌិតទេ*</u> ។

ហេតុដូចនេះ តុលាការមិនត្រូវយកបញ្ញត្តិនៃមាត្រា៦០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល មកអនុវត្តឡើយ ។

- អង្គហេតុដែលតុលាការយកមកពិនិត្យ នៅមានសង្ស័យ មិនច្បាស់លាស់នៅឡើយ។ ដោយហេតុថាអង្គហេតុមិនបាននិយាយអំពី ព្យសនកម្មដែលបណ្តាលមកពីបទល្មើសឡើយ។ ម៉្យាងវិញទៀត អង្គហេតុមិនបានបង្ហាញនូវអំពើប្រព្រឹត្តបទល្មើសដោយផ្ទាល់របស់ជនជាប់ចោទទាំង១១ នាក់ឡើយ ។
- នៅក្នុងសំអាងហេតុរបស់ខ្លួន តុលាការមិនបានឆ្លើយតបអំពីការរកឃើញ របស់ខ្លួនអំពីការបដិសេធនៃជនជាប់ចោទឡើយ ដោយតុលាការគ្រាន់តែសំអាងហេតុថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការប្រាកដមែន និង ការយល់ឃើញថាមានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់ មកលើជនជាប់ចោទ ជាការស្រេច ។ យើងមិនបានឃើញថាភស្តុតាងអ្វីខ្លះ ដែលធ្វើអោយចៅក្រមជឿលើសពីការសង្ស័យថា ជនជាប់ចោទមានចេតនាប្រព្រឹត្ត និងបានប្រព្រឹត្តនូវអំពើល្មើស។

VI. <u>អនុសាសន៍</u>

តុលាការត្រូវពិនិត្យមើលនូវដីកាប្តឹងមកតុលាការដើម្បីស្នើសុំអោយមានការជំនុំជម្រះ ថាតើដីកាដែលប្តឹងមកនេះត្រឹមត្រូវតាមគតិច្បាប់នៃមាត្រា ២៩១ ឬទេ ។

តុលាការត្រូវពិនិត្យមើលអំពីអង្គច្បាប់ នៃការអនុវត្តក្រមព្រហ្មទណ្ឌថ្មីឆ្នាំ២០០៩ នូវបញ្ញត្តណាដែលស្រាលជាង ឬធ្ងន់ជាង នៅពេលដែលខ្លួនធ្វើការសំរេចក្តីនៃសំណុំរឿងនេះ ។

នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តុលាការត្រូវបង្ហាញនូវទឡ្ហីករណ៍នៃអង្គហេតុ និង អង្គច្បាប់ ដែលគ្មានវិមតិសង្ស័យ និង មានភស្តុតាដែលជឿជាក់ថា ជនជាប់ចោទប្រព្រឹត្តបទចោទ លើសពីការសង្ស័យ ។

---